ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ៣៨ អនក្រ.បក

# អនុក្រឹត្យ
# ស្ដីពី
# ការបង្កើតគណៈកម្មការសមាហរណកម្មមន្ត្រីរាជការស៊ីវិល
# ទៅក្នុងក្របខ័ណ្ឌថ្មី

## រាជរដ្ឋាភិបាល

– បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
– បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
– បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការចាត់តាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
– បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពី សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
– បានឃើញព្រះរាជក្រឹត្យលេខ ជស.រកត. ១២៩៧-២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ១៩៩៧ ស្ដីពីគោលការណ៍ រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
– តាមសំណូមពរចាំបាច់នៃការងារ

## សម្រេច

**មាត្រា ១.–**

ត្រូវបានបង្កើតគណៈកម្មការសមាហរណកម្មមន្ត្រីរាជការស៊ីវិលទៅក្នុងក្របខ័ណ្ឌថ្មី ដើម្បីផ្ទេរបញ្ចូលទៅក្នុងក្របខ័ណ្ឌថ្មីទាំងបួនប្រភេទៈ **ក ខ គ ឃ** នូវមន្ត្រីរាជការស៊ីវិលទាំងឡាយ ដែលបច្ចុប្បន្នកំពុងបំពេញមុខតំណែង និងមុខងារពិតប្រាកដរបស់ក្របខ័ណ្ឌនៅក្នុងរដ្ឋបាលកណ្ដាល និងតាមខេត្ត ក្រុងទូទាំងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ២.–**

គណៈកម្មការសមាហរណកម្មមន្ត្រីរាជការស៊ីវិលទៅក្នុងក្របខ័ណ្ឌថ្មី មានសមាសភាពដូចខាងក្រោម:

| | |
|---|---|
| ១- អគ្គលេខាធិការក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល | ប្រធាន |
| ២- រដ្ឋលេខាធិការមុខងារសាធារណៈ | អនុប្រធាន |
| ៣- សមាជិកអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល | សមាជិកអចិន្ត្រៃយ៍ |
| ៤- តំណាងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ | សមាជិក |
| ៥- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៦- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៧- តំណាងក្រសួងមហាផ្ទៃ | សមាជិក |
| ៨- តំណាងក្រសួងសុខាភិបាល | សមាជិក |
| ៩- តំណាងក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ១០- តំណាងក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់ | សមាជិក |
| ១១- តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១២- តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១៣- តំណាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ១៤- តំណាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |

**មាត្រា ៣.–**

ប្រធានគណៈកម្មការ មានសិទ្ធិអញ្ជើញអ្នកបច្ចេកទេស ឬតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធឯទៀតចូលរួមប្រជុំតាមការចាំបាច់។

**មាត្រា ៤.–**

គណៈកម្មការសមាហរណកម្មមន្ត្រីរាជការស៊ីវិលទៅក្នុងក្របខ័ណ្ឌថ្មី មានភារកិច្ចដូចតទៅ:

១- ពិនិត្យសិក្សាស្រាវជ្រាវ ណែនាំរៀបចំលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីរាជការផ្សេងៗទៀតក្រៅពីក្របខ័ណ្ឌមន្ត្រីរដ្ឋបាល ក្នុងករណីចាំបាច់ជាមួយក្រសួងពាក់ព័ន្ធ

២- សិក្សាស្រាវជ្រាវលើកគោលការណ៍សម្រាប់ការចាត់ថ្នាក់ធ្វើសមាហរណកម្មមន្ត្រីរាជការបញ្ចូលទៅក្នុងក្របខ័ណ្ឌថ្មី ជូនរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច

៣- រៀបចំកម្មវិធីសមាហរណកម្ម ដាក់ឱ្យអនុវត្ត និងណែនាំ តាមដានការអនុវត្តកម្មវិធី នៅតាមក្រសួង ស្ថាប័ននានា

៤- ធ្វើសុពលកម្មលទ្ធផលនៃការធ្វើសមាហរណកម្មមន្ត្រីរាជការស៊ីវិល បញ្ចូលទៅក្នុងក្របខ័ណ្ឌថ្មីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច

៥- ធ្វើសហប្រតិបត្តិការជាមួយរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ផ្ទៀងផ្ទាត់បញ្ចូលទិន្នន័យថ្មីនៃការងារសមាហរណកម្ម ទៅក្នុងប្រព័ន្ធគ្រប់គ្រងព័តិមានវិទ្យា។

**មាត្រា ៥.–**

គណៈកម្មការនេះ ស្ថិតនៅទីស្តីការគណៈរដ្ឋមន្ត្រីក្រោមការគ្រប់គ្រងផ្ទាល់របស់ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ។

**មាត្រា ៦.–**

គណៈកម្មការសមាហរណកម្មមន្ត្រីរាជការស៊ីវិលទៅក្នុងក្របខ័ណ្ឌថ្មី ធ្វើការក្រោមការដឹកនាំរបស់ប្រធានគណៈ-កម្មការ ហើយមានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី និងបុគ្គលិករបស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ជាជំនួយការតាមការចាំបាច់ ។

**មាត្រា ៧.–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការ-ដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី និងរដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងឯកឧត្តម អស់លោក ដូចមានចែងក្នុងមាត្រា ២ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០០០

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន

សម្តេចនាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា

**ប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល**

**សុខ អាន**

***កន្លែងទទួល***

- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋាននៃរាជរដ្ឋាភិបាល
- គ្រប់ក្រសួង ស្ថាប័នរដ្ឋ
- ដូចមាត្រា ៧
- ឯកសារ–កាលប្បវត្តិ